ចុះផ្សាយនៅកាសែត ភ្នំពេញប៉ុស្តិ៍ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥

# ឱ ភ្នំពេញអើយ!៖ គិតឡើងវិញពីការអភិវឌ្ឍរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន

ឱ ភ្នំពេញអើយ! គឺជាបទចម្រៀងដ៏ស្រងេះស្រងោចមួយដែលត្រូវបាននិពន្ធឡើងកាលពីដើមទសវត្សរ៍១៩៨០ ដោយលោក កែវ ចិន្តា អតីតអភិបាលក្រុងភ្នំពេញ។ វាជាចម្រៀងមួយដែលបានរៀបរាប់ពីជីវិតជូរចត់ និងមនោសញ្ចេតនាចំពោះទីក្រុងភ្នំពេញដែលជារាជធានីរបស់កម្ពុជាក្រោយការដួលរលំរបបខ្មែរក្រហម ដែលនៅក្នុងសម័យនោះភ្នំពេញបានក្លាយជាទីក្រុងខ្មោចដោយមានផ្ទះតែគ្មានមនុស្សនៅ និងមានផ្លូវតែគ្មានមនុស្សដើរ។

ជាងសាមសិបឆ្នាំក្រោយ, ប្រជាជនដែលរស់នៅភ្នំពេញនៅតែច្រៀងបទខាងលើដដែល។ ប៉ុន្តែនៅពេលនេះចម្រៀងនេះមិនមែនរៀបរាប់អំពីទីក្រុងភ្នំពេញដែលមានផ្ទះឥតមនុស្សនៅ និងមានផ្លូវឥតមនុស្សដើរ ដូចកាលពីសម័យមុនឡើយ។ តែជាទុក្ខព្រួយដែលកើតឡើងដោយសារផ្លូវដែលកកស្ទះចរាចរណ៍, ដីហុយ, គ្រោះថ្នាក់ចរាចរណ៍, សុវត្ថិភាពក្នុងការធ្វើដំណើរនិងការរស់នៅប្រចាំថ្ងៃ, ការលិចទឹកក្រោយពេលមានភ្លៀងធ្លាក់ម្តងៗ ដែលផ្ទះសំបែង និងកន្លែងធ្វើការរបស់ប្រជាជនខ្លះត្រូវទឹកស្អុយហូរចូល ហើយកន្លែងលិចទឹកខ្លះមានជម្រៅអាចហែលបាន។ល។

ការលិចជំនន់ទឹកភ្លៀងគឺជាបញ្ហាដ៏ធំមួយដែលកំពុងតែប៉ះពាល់ដល់សុខមាលភាព និងការងាររបស់ប្រជាជនរស់នៅភ្នំពេញ។ មូលហេតុចំបងនៃការលិចជំនន់ទឹកភ្លៀងត្រូវបានគេមើលឃើញថាបណ្តាលមកពីប្រព័ន្ធបង្ហូរ និងអាងស្តុបសម្រាប់រំដោះទឹកចេញពីផ្លូវ និងលំនៅដ្ឋានរបស់ប្រជាជនមិនល្អ, ស្ទះ ឬត្រូវបានគេចាក់ដីបំពេញ ជាពិសេសគឺការចាក់ដីលប់បឹង និងផ្លូវទឹកទាំងឡាយនៅក្នុងរាជធានីភ្នំពេញដែលធ្លាប់ជាអាងស្តុប និងប្រព័ន្ធរំដោះទឹកបែបធម្មជាតិនៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។

តាមពិតទៅវត្តមានបឹងបួរ និងប្រឡាយទាំងឡាយនៅក្នុងរាជធានីភ្នំពេញ និងតំបន់ជុំវិញទីក្រុងនេះមិនមែនកើតឡើងដោយចៃដន្យ និងឥតប្រយោជន៍ឡើយ។ បឹងទាំងនោះខ្លះជាបឹងធម្មជាតិ ហើយខ្លះទៀតគឺជាបឹងដែលត្រូវបានគេជីកបង្កើតឡើងដើម្បីទប់ទល់ និងរំដោះទឹកជំនន់ ពីព្រោះទីតាំងភូមិសាស្ត្រនៅភ្នំពេញគឺជាដីទំនាបនៅជាប់នឹងដងទន្លេដែលងាយរងគ្រោះដោយសារទឹកជំនន់ និងទឹកភ្លៀង។ បឹងទាំងនោះក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យមានតុល្យភាពនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងទីក្រុងនេះផងដែរ។ ប៉ុន្តែផ្ទុយទៅនឹងទស្សនវិជ្ជា និងគោលនយោបាយនៃការកសាងរាជធានីភ្នំពេញពីអតីតកាល, ការអភិវឌ្ឍទីក្រុងភ្នំពេញនៅក្នុងទសវត្សរ៍ចុងក្រោយនេះហាក់បីដូចជាបំភ្លេច និងមិនយកចិត្តទុកដាក់ពីមុខងារ និងសារៈសំខាន់នៃបឹងនិងផ្លូវទឹកទាំងនោះ។ ដោយសារអំពើពុករលួយ និងការគិតតែប្រយោជន៍ផ្ទាល់ខ្លួន, បឹង និងផ្លូវទឹកទាំងឡាយនៅក្នុងទីក្រុងភ្នំពេញ និងតំបន់ជុំវិញត្រូវបានបុគ្គល និងក្រុមហ៊ុនឯកជនដោយមានការឃុបឃិតជាមួយសមត្ថកិច្ចពុករលួយបានចាក់ដីលប់ស្ទើរតែគ្មានសល់ ក្រោមរូបភាពនៃការ

អភិវឌ្ឍ។ ការអភិវឌ្ឍបែបនេះក៏ផ្ទុយនឹងគោលនយោបាយនៃការអភិវឌ្ឍទីក្រុងនៅក្នុងប្រទេសមួយចំនួននៅអាស៊ីអាគ្នេយ៍ផងដែរ។ ឧទាហរណ៍នៅក្នុងឆ្នាំនេះអាជ្ញាធរទីក្រុងហូជីមិញរបស់វៀតណាមមិនត្រឹមតែមិនលប់បឹងនៅក្នុងទីក្រុងរបស់គេទេ ប៉ុន្តែគេថែមទាំងមានគោលនយោបាយជីកបឹងថ្មីចំនួន៣០ បន្ថែមទៀតដើម្បីបញ្ចៀសជំនន់ទឹកភ្លៀង និង ទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។

តើការអភិវឌ្ឍទីក្រុងភ្នំពេញនាបច្ចុប្បន្នជាការអភិវឌ្ឍអ្វី? ហើយដើម្បីនរណា? ជាការពិតការអភិវឌ្ឍបែបនេះគឺដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួនរបស់បុគ្គលមួយក្រុមតូចតែប៉ុណ្ណោះ។ វាមិនបានគិតគូរដល់សុខមាលភាព, សុវត្ថិភាព ,និរន្តភាព និងប្រយោជន៍សាធារណៈជាធំឡើយ។ ទង្វើនេះបាននឹងកំពុងធ្វើឲ្យទីក្រុងភ្នំពេញស្ថិតនៅក្នុងស្ថានភាពគំរាមកំហែង និងគ្រោះថ្នាក់ដែលគួរឲ្យព្រួយបារម្ភ។ ការបាត់បង់បឹងទាំងនោះបានធ្វើឲ្យទីក្រុងភ្នំពេញបាត់បង់តុល្យភាពធម្មជាតិ (ទឹក, ដី, ភ្លើង, ខ្យល់) និងមនុស្សផងដែរ ដែលវាប៉ះពាល់ដល់សុខមាលភាពរបស់ប្រជាជនដែលកំពុងតែរស់នៅ និងសេដ្ឋកិច្ចក្នុងទីក្រុងនេះ។ ការបាត់បង់អាងស្តុក និងបញ្ចៀសទឹកធម្មជាតិក៏នាំឲ្យកម្ពុជាត្រូវចំណាយប្រាក់រាប់លានក្នុងមួយឆ្នាំៗលើការបូបទឹកកខ្វក់ និងទឹកភ្លៀងចេញពីលំនៅដ្ឋាន។ ការអភិវឌ្ឍបែបនេះមិនធ្វើឲ្យទីក្រុងភ្នំពេញមាននិរន្តភាពឡើយ ប៉ុន្តែអន្តរាយ។

ខ្មែរនៅសម័យអង្គរត្រូវបានគេទទួលស្គាល់ថាជាកំពូលជាតិសាសន៍ដែលពូកែគ្រប់គ្រងទឹក និងប្រើប្រាស់ទឹកក្នុងការធ្វើកសិកម្ម និងការកសាងប្រាសាទជាដើម។ វាគួរឲ្យខ្មាសបុព្វបុរសខ្មែរជំនាន់មុនដែលដោយសារតែការលោភលន់ និងការអភិវឌ្ឍដោយគិតតែផលប្រយោជន៍រយៈពេលខ្លី, ខ្មែរនៅភ្នំពេញសម័យនេះបានក្លាយជាជនរងគ្រោះសូម្បីដោយសារតែជំនន់ទឹកភ្លៀង។ សេចក្តីលោភលន់, ការគិតតែប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍រយៈពេលខ្លីមិនត្រឹមតែធ្វើឲ្យទីក្រុងភ្នំពេញលិចលង់ប៉ុណ្ណោះទេ, វាក៏នឹងធ្វើឲ្យសង្គមជាតិខ្មែរទាំងមូលអន្តរាយផងដែរ។

ប៉ា ចំនួរឿន
អ្នកស្រាវជ្រាវផ្នែកទស្សនវិជ្ជា&ការអភិវឌ្ឍ និងជាប្រធានមជ្ឈមណ្ឌលទស្សនវិជ្ជាអនុវត្តន៍ និងសីលធម៌កម្ពុជា
អ៊ីម៉េ2ល៖ chanroeunkh@gmail.com